UNITED NATIONS
OFFICE OF THE HIGH COMMISSIONER
FOR HUMAN RIGHTS IN CAMBODIA

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

**អង្គការសហប្រជាជាតិ**
**ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា**

OHCHR

# សភាកម្ពុជាប្រារព្ធពិធីអបអរសាទរខួបលើកទី៦០
# នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស(១៩៤៨-២០០៨)

សេចក្តីថ្លែងការណ៍ដោយលោកគ្រីស្តូហ្វ ប៉េស៊ូ

តំណាងការិយាល័យឧត្តមស្នងការអ.ស.បទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

**ឯកឧត្តម លោកជំទាវជាទីស្នេហា,**

**សមាជិក សមាជិកានៃរដ្ឋសភា និងព្រឹទ្ធសភាដ៏ឧត្តុង្គឧត្តម**

ខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយដើម្បីធ្វើសន្ទរកថាដ៏ខ្លីនៅចំពោះមុខអង្គសភាដ៏ឧត្តុងឧត្តមនៅក្នុងឱកាសខួបលើកទី៦០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស(UDHR) ។

ខ្ញុំសូមផ្តើមដោយការរំលឹកឡើងវិញអំពីកត្តាសំខាន់ៗមួយចំនួនអំពីសេចក្តីប្រកាសនេះ :

*" មនុស្សទាំងអស់កើតមកមានសេរីភាពនិងសមភាពក្នុងផ្នែកសេចក្តីថ្លៃថ្នូរ និងសិទ្ធិ....." ។*

*" បុគ្គលម្នាក់ៗមានសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខផ្ទាល់ខ្លួន..." ។*

*" មនុស្សគ្រប់រូបមានសិទ្ធិ ស្មើគ្នាចំពោះមុខច្បាប់ "។*

ក្រៅពីនេះ សេចក្តីប្រកាសនេះបង្កើតបញ្ជីសិទ្ធិមួយចំនួនរាប់ពី :

- សិទ្ធិមិនត្រូវបានគេធ្វើទារុណកម្ម សិទ្ធិមិនត្រូវបានគេយកធ្វើជាទាសករ ឬសិទ្ធិមិនត្រូវបានគេឃុំឃាំងតាមទំនើងចិត្ត
- សិទ្ធិសេរីភាពក្នុងការសំដែងមតិយោបល់ និងសិទ្ធិប្រតិបត្តិសាសនា
- សិទ្ធិអប់រំ សិទ្ធិសុខភាព និងសិទ្ធិទទួលប្រាក់ឈ្នួលស្មើគ្នាចំពោះការងារមានតម្លៃស្មើគ្នា ។

No. 10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh Cambodia
Tel: +(855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342  Fax: +(855) 23 212 579 or 213 587
e-mail: cambodia@ohchr.org  Website: http://cambodia.ohchr.org

សេចក្តីប្រកាសនេះចែងថាមនុស្សម្នាក់ៗអាចប្រើប្រាស់សិទ្ធិ និងសេរីភាពទាំងអស់ " *ដោយគ្មានការប្រកាន់បែងចែកណាមួយ មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយឬមតិផ្សេងៗទៀត....* "។

សេចក្តីប្រកាសនេះចែងផងដែរថា " *ការទទួលស្គាល់សេចក្តីថ្លៃថ្នូរ ជាប់ពីកំណើត និងសិទ្ធិស្មើភាពគ្នា និងសិទ្ធិមិនអាចលក់ ដូរ ផ្ទេរ ឬដកហូតបានរបស់សមាជិកទាំងអស់នៃគ្រួសារមនុស្ស គឺជាគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពក្នុងពិភពលោក* "។

**ឯកឧត្តមជាទីស្នេហា**

ដូចលោកជ្រាបស្រាប់ហើយ មាត្រា៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សជាផ្នែកមួយនៃច្បាប់កម្ពុជា។ នេះជារឿងមួយមិនធម្មតាទេនៅក្នុងប្រទេសមួយ ព្រោះថាសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សមិនមែនជាសន្ធិសញ្ញាភ្ជាប់កាតព្វកិច្ចនោះទេ ប៉ុន្តែសំរាប់ប្រទេសកម្ពុជាសន្ធិសញ្ញានេះមានលក្ខណៈចាប់បង្ខំឱ្យអនុវត្ត ដែលនេះជារឿងមួយគួរឱ្យមោទនបំផុត។

ឆ្នាំនេះវាមិនត្រឹមតែជាខួបលើកទី៦០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាការអបអរសាទរខួបកំណើតលើកទី១៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ ជំពូកទី៣ នៃរដ្ឋធម្មនុញ្ញ - ការតម្រូវរបស់កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស - តំលៃនៃការប្រកាសរបស់កម្ពុជាអំពីសិទ្ធិមនុស្សបានធ្វើយ៉ាងត្រឹមត្រូវនៅចំណុចដែលថាសិទ្ធិមនុស្សគឺមិនមែនជាប្រណិតភាព ឬជាជំរើសនោះទេ ប៉ុន្តែវាជាស្នូលនៃច្បាប់កម្ពុជា។ គោលការណ៍នេះត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងខែកក្កដា ឆ្នាំ២០០៧ ដោយសេចក្តីសំរេចជាគន្លឹះមួយរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

នៅពេលធ្វើបានព្រៀងរដ្ឋធម្មនុញ្ញក្នុងឆ្នាំ១៩៩៣ សមាជិកសភាធម្មនុញ្ញទំនងជាៗអ្នកដែលបានតាក់តែងសេចក្តីប្រកាសនេះក្នុងឆ្នាំ១៩៤៨។ ពួកគេបានរំលឹកអំពីសម័យកាលដ៏ខ្មៅងងឹតនៃប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាកាលពីបីទសវត្សរ៍កន្លងមក។ ហើយពួក គេបានគិតគូរដល់ការដាក់បញ្ចូលសេចក្តីប្រកាសនេះទៅក្នុងរដ្ឋធម្មនុញ្ញ - ដែលជាច្បាប់គ្រឹះបំផុតមួយនៃព្រះរាជាណាចក្រកម្ពុជាសំរាប់អនុវត្តច្រើនឆ្នាំទៅមុខ - ដើម្បីធានាការពារមិនឱ្យមានការវិញត្រឡប់ជាថ្មីនូវសម័យកាលដ៏ខ្មៅងងឹតដែលពោរពេញទៅដោយការភ័យខ្លាច ការឈឺចាប់ ការស្លាប់ និងសោកនាដកម្ម។ ពួកគេបានគិតថា ពេលនេះមានសុខសន្តិភាពហើយៗតើគេត្រូវធ្វើយ៉ាងណាដើម្បីពង្រឹងសន្តិភាពនោះបាន និងការស្ថាបនាឡើងវិញនូវមាតុភូមិកម្ពុជា ដើម្បីធានាថាវាជាប្រទេសជាតិមួយដែលមានមនុស្សធម៌សំរាប់មនុស្សគ្រប់រូប។ ពួកគេបានងាកទៅមើលសេចក្តីប្រកាសកាលពី

ដើមដំបូងដែលបានតាក់តែងដូចគ្នាបេះបិទដើម្បីគោលបំណងនេះ ៖ តើត្រូវធ្វើយ៉ាងណាដើម្បីអាចទប់ស្កាត់ការវិលត្រឡប់ជាថ្មីនូវគោលនយោបាយ និងការអនុវត្តន៍កន្លងមកបាន ? ។

ពួកគេបានដឹងថា បន្ទាប់ពីឆ្លងកាត់ការឈឺចាប់រយៈពេលជាច្រើនឆ្នាំមក សិទ្ធិមនុស្សមិនមែនជាគោលការណ៍មួយដែលអរូបីយឡើយ ផ្ទុយទៅវិញវាបានឆ្លុះបញ្ចាំងអំពីបំណងប្រាថ្នារបស់មនុស្សទូទៅក្នុងការរស់នៅជាមនុស្ស ទទួលបានសិទ្ធិពេញលេញ និងអំពីថាតើយើងរាល់គ្នា លោកអ្នក និងខ្ញុំ មាតាបិតា កូនប្រុសស្រី គ្រួសារ មិត្តភក្តិ និងជនរួមជាតិប្រុសស្រីទាំងអស់របស់យើង ចង់បានឱ្យអ្នកដទៃ និងរដ្ឋាភិបាលប្រព្រឹត្តបែបណាមកលើខ្លួនយើង ។

ដូច្នេះក្នុងន័យនេះហើយទើបសេចក្តីប្រកាសនេះមានលក្ខណៈសកល ។ ខ្ញុំមិនដឹងថាមានមនុស្សណាម្នាក់ចង់ឱ្យគេសំលាប់ ធ្វើទារុណកម្ម ចាប់ដាក់ពន្ធនាគារដោយទទេៗ ដោយសារតែការកាត់សេចក្តីដោយតុលាការពុករលួយ អាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានគេរាំងមិនឱ្យទទួលការអប់រំ កិច្ចគាំពារសុខភាព ឬមុខរបរ ដោយសារតែគេជាក្មេងប្រុស ឬជាក្មេងស្រី ឬព្រោះតែពួកគេជាអ្នកក្រ ឬនិយាយភាសាផ្សេងពីគេនោះឡើយ ។

មនុស្សគ្រប់រូបនៅកម្ពុជាយល់ដឹងអំពីតំលៃនៃការផ្លាស់ប្តូររដ្ឋាភិបាល តាមរយៈមធ្យោបាយសន្តិវិធី ។

ដូច្នេះសិទ្ធិមនុស្សឆ្លុះបញ្ចាំងពីបំណងប្រាថ្នាជាសកលរបស់មនុស្សជាតិដើម្បីទទួលបានភាពរបស់ខ្លួនជាមនុស្ស ។

ភាពរបស់យើងទាំងអស់គ្នាជាមនុស្ស ។

ពិតណាស់នេះគឺជាឧត្តមគតិមួយ ។ ប៉ុន្តែយើងត្រូវការឱ្យមានទស្សនវិស័យនៃគំនិតដ៏ឧត្តុង្គឧត្តមនេះ ដើម្បីលើកកំពស់ខ្លួនយើងឱ្យផុតពីដី និងទទួលបានភាពជាមនុស្សរបស់យើងទាំងអស់គ្នា ។ ខ្ញុំជឿថាបើគ្មានគំនិតនេះទេ បើគ្មានការស្រមើលស្រមៃ(សុបិន) របស់ពិភពលោកដែលយើងចង់រស់នៅទេនោះ ជីវិតនឹងក្លាយជាពន្ធនាគារមួយដ៏សែនតូចចង្អៀត ។

យើងត្រូវការមានឧត្តមគតិមួយដើម្បីអាចឆ្លុះបញ្ចាំងខ្លួនឯងនៅថ្ងៃអានាគត និងកសាងពិភពលោកមួយដែលយើងចង់រស់នៅ និងមានសុទិដ្ឋិនិយមថាយើងនឹងសំរេចបានជាបន្តើរៗ ។

ខ្ញុំសូមងាកមកនិយាយអំពីតួនាទីរបស់សមាជិកសភានិងព្រឹទ្ធសភាវិញម្តង ៖

ដោយផ្អែកលើមូលដ្ឋានគ្រឹះនេះ តួនាទីរបស់លោកគឺការតាក់តែងច្បាប់ ហើយដើម្បីអាចធ្វើដូច្នេះបាន ត្រូវធានាថាច្បាប់ទាំងនោះស្របតាមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ និងសន្ធិសញ្ញាឯទៀតដែលកម្ពុជាបានអនុម័តទទួលយក ដើម្បីឱ្យច្បាប់ទាំងនោះមានបញ្ញត្តិដែលធានាការពារជាពិសេសដល់សិទ្ធិប្រជាពលរដ្ឋកម្ពុជាគ្រប់រូបដោយអនុលោមតាមរដ្ឋធម្មនុញ្ញ ។

ការិយាល័យយើងខ្ញុំ ( ការិយាល័យឧត្តមស្នងការអ.ស.បទទួលបន្ទុកសិទ្ធិមនុស្ស) មានតួនាទីផ្តល់កិច្ចសហប្រតិបត្តិការជាមួយតំណាងរាស្ត្រ និងរដ្ឋាភិបាលក្នុងទម្រង់ជាការផ្តល់ប្រឹក្សាយោបល់ជំនាញផ្នែកច្បាប់ដើម្បីធានាថាច្បាប់ទាំងនោះស្របតាមសន្ធិសញ្ញាទាំងនេះ ។

មានច្បាប់សំខាន់បំផុតមួយចំនួនដែលត្រូវស្ថិតនៅចំពោះមុខអស់លោកនៅក្នុងនីតិកាលខាងមុខនេះ :

១- ក្រមព្រហ្មទណ្ឌ

២- ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់តុលាការ

៣- ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម

៤- វិសោធនកម្មច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

៥- ច្បាប់ប្រឆាំងអំពើពុករលួយ

៦- ច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី

៧- ច្បាប់ស្តីពីអង្គការក្រៅរដ្ឋាភិបាល

ការិយាល័យយើងខ្ញុំត្រៀមខ្លួនជាស្រេច ដូចដែលធ្លាប់មានកន្លងមកតាំងពីឆ្នាំ១៩៩៣ ដើម្បីធ្វើការយ៉ាងជិតស្និទ្ធជាមួយសមាជិកសភាដែលពាក់ព័ន្ធ និងគណៈកម្មការទាំងអស់របស់រដ្ឋសភា និងព្រឹទ្ធសភា ដើម្បីផ្តល់ព័ត៌មានដែលទាក់ទងនឹងច្បាប់ ការជួយឧបត្ថម្ភ និងការផ្តល់ប្រឹក្សាយោបល់ក្នុងការតាក់តែងច្បាប់ទាំងនេះ ។ សូមលោកមេត្តាទទួលយកការជួយឧបត្ថម្ភអំពីយើងខ្ញុំ តាមការគួរ ។

យោបល់ចុងក្រោយរបស់ខ្ញុំគឺនឹងនិយាយអំពីច្បាប់ និងការអនុវត្តច្បាប់ ។

ចាប់តាំងពីឆ្នាំ១៩៩៣ មានច្បាប់ជាច្រើនត្រូវបានអនុម័តដោយរដ្ឋសភា និងព្រឹទ្ធសភា ។ ច្បាប់ទាំងនេះភាគច្រើនគឺជាច្បាប់ដែលល្អ និងមានបញ្ញត្តិសំខាន់ៗដែលធានាការពារសិទ្ធិរបស់ប្រជាពលរដ្ឋមិនឱ្យមានការរំលោភបំពាន ឬការរិតត្បិតតាមទំនើងចិត្ត ។ ប៉ុន្តែយើងខ្ញុំក៏ដឹងដែរថានៅក្នុងប្រទេសនេះ ក៏ដូចជានៅក្នុងប្រទេសឯទៀតភាគច្រើន ច្បាប់ល្អអាចមានប្រយោជន៍ទៅបានគឺវាអាស្រ័យទៅលើការអនុវត្តន៍ឱ្យបានសមរម្យក្នុងលក្ខណៈត្រឹមត្រូវ និងដោយស្មើភាពគ្នា ។ ប្រសិនជាយើងលើកជាឧទាហរណ៍អំពីច្បាប់ភូមិបាលឆ្នាំ ២០០១ ដែលជាច្បាប់មួយដែលសំខាន់សំរាប់ប្រជាពលរដ្ឋកម្ពុជារាប់លាននាក់នោះ យើងខ្ញុំដឹងថាប្រសិនជាច្បាប់នេះត្រូវបានអនុវត្តមានប្រសិទ្ធភាពនោះៗ បញ្ហាវិវាទ ឬទំនាស់ដីធ្លីដែលយើងសង្កេតឃើញមាននៅទូទាំងប្រទេសអាចនឹងបញ្ចៀសបាន ឬអាចដោះស្រាយបានដោយសន្តិវិធី ។

ដោយសារនៅពេលបន្តិចទៀតនេះនឹងមានការពិភាក្សាគ្នា ដូច្នេះប្រហែលនឹងមានប្រយោជន៍ដើម្បីស្តាប់មតិយោបល់របស់តំណាងរាស្ត្រអំពីបញ្ហានេះ និងថាតើសភាមានបំណងធ្វើដូចម្តេចខ្លះចំពោះបញ្ហានេះក្នុងការពង្រឹងការអនុវត្តន៍ច្បាប់?

ឆ្លៀតឱកាសនេះ ខ្ញុំសូមសំដែង ចំពោះសមាជិកសមាជិការដ្ឋសភា និងព្រឹទ្ធសភាដ៏ឧត្តុង្គឧត្តមទាំងអស់នូវការអបអរសាទរយ៉ាងកក់ក្តៅ និងសូមជូនពរឱ្យអស់លោកបានទទួលជ័យជំនះក្នុងការងារសំរាប់នីតិកាលនេះ និងសូមឱ្យការប្រារព្ធអបអរសាទរទិវាសិទ្ធិមនុស្សនៅថ្ងៃស្អែកបានប្រកបដោយភាពអធិកអធម ។

**ចប់**